# “ការងារប្រក់ដំបូល”

## ចំណុចសំខាន់សម្រាប់សុវត្ថិភាពនិងសុខភាព

## កៅឡាក់, បទដ្ឋានសុវត្ថិភាពក្នុងការផ្អាកការងារដោយសារអាកាសធាតុមិនអំណោយផល

### (1) ជំនាញប្រើប្រាស់កៅឡាក់ (ដងយោង)





**បញ្ហាដែលត្រូវអនុវត្ត**

ប្រតិបត្តិការកៅឡាក់ (ម៉ាស៊ីនយោង) សម្រាប់ការងារស្ទូចយោង ឬការងារស្រដៀងគ្នានេះ គឺត្រូវធ្វើឡើងដោយអ្នកដែលបានទទួលការ “បណ្តុះបណ្តាលពិសេសអំពីប្រតិបត្តិការម៉ាស៊ីនយោង”។

## (2) ហាមមនុស្សជិះនៅលើបង្គោលយោងក្បឿង (ហាមជិះលើទូយោង)



### បញ្ហាដែលត្រូវអនុវត្ត

1. ហាមមនុស្សជិះពីលើទូយោង។
2. អ្នកមិនគួរឡើងនិងចុះតាមជណ្តើរនៃជងយោងក្បឿងដំបូលឡើយ។

## (3) ហាមធ្វេសប្រហែស (ចូរផ្តោតទៅលើបន្ទុកខណៈពេលកំពុងប្រតិបត្តិការ)



### បញ្ហាដែលត្រូវអនុវត្ត

1. ហាមលើកបន្ទុករំលងពីលើក្បាល។
2. ហាមចូលក្រោមរទេះ ឬទូរយោងដែលកំពុងដំណើរការ។
3. ហាមប្រតិបត្តិការតាមរបៀបមួយដែលបន្ទុកឬជណ្តើរយោល។
4. ហាមដំណើរការនៅពេលមានមនុស្សស្ថិតនៅក្នុងវង់ប្រតិបត្តិការនៃរទេះ/ទូយោង។

## (4) បង្ការការទាក់ជាប់ (អំឡុងពេលប្រតិបត្តិការ ហាមប៉ះស្គរឬខ្សែកាប)




### បញ្ហាដែលត្រូវអនុវត្ត

1. ហាមប៉ះខ្សែកាបយោង។
2. ពាក់សម្លៀកបំពាក់រឹបរាង និងហាមពាក់គ្រឿងអលង្ការ ដូចជាខ្សែកដាដើម។

## (5) ការបំពេញការងារនៅពេលមានខ្យល់ខ្លាំងឬព្យុះ (ល្បឿនខ្យល់មធ្យមក្នុងរយៈពេល 10 នាទីគឺ 10 ម៉ែត្រ/វិនាទី ឬលើសនេះ)

○ ការបំពេញការងារនៅពេលមានខ្យល់ខ្លាំងឬព្យុះមានគ្រោះថ្នាក់ណាស់។

1. បង្ការសុវត្ថិភាពផ្ទាល់ខ្លួន។
2. ឈប់បំពេញការងារនៅលើដំបូលនៅពេលមានខ្យល់ខ្លាំង។
3. ចូរការពារកែង្រលោសម្ភារប៉ើងនិងធ្លាក់។
4. ប្រសិនបើស្ទាក់ស្ទើក្នុងការធ្វើការងារលើដំបូល ចូរប្រើប្រព័ន្ធបង្ការការធ្លាក់ (ចង្វាយខ្សែបង្ការការធ្លាក់) ជាមួយខ្សែសុវត្ថិភាព។

ឧទាហរណ៍



នៅពេលជនរងគ្រោះកំពុងដំឡើងផ្ទាំងសូឡាម្នាក់ឯង, ខណៈពេលកំពុងដឹកជញ្ជូនផ្ទាំងសូឡានៅលើដំបូល, គាត់ត្រូវបានខ្យល់គួចស្ទើប៉ើងដោយដៃកាន់ផ្ទាំងសូឡានោះ។

## (6) បំពេញការងារនៅពេលកំពុងភ្លៀងខ្លាំង (កម្ពស់ទឹកភ្លៀង 50 ម.ម ឬលើសនេះ)



**បញ្ហាដែលត្រូវអនុវត្ត**

1. ហាមប្រើឧបករណ៍អគ្គិសនីក្រែងលោធក់។
2. ចូរប្រយ័ត្នជើងពីព្រោះដំបូលរអិល។
3. បន្ទាប់ពីភ្លៀងរួច ចូរពិនិត្យមើលប្រព័ន្ធអគ្គិសនីនិងឧបករណ៍មុននឹងបំពេញការងារ។

## (7) ការបំពេញការងារនៅពេលមានព្រិលឬទឹកកកធ្លាក់ខ្លាំង

### 1. ការបំពេញការងារពេលមានព្រិលធ្លាក់

**បញ្ហាដែលត្រូវអនុវត្ត**

1. នៅពេលមានទឹកកក ហាមឡើងលើដំបូល។
2. បន្ទាប់ពីទឹកកករលាយនិងដំបូលស្ងួត ទើបអាចឡើងលើដំបូលបាន។
3. នៅពេលបំពេញការងារ ចូរដាក់បាំងទឹកកកមួយថ្ងៃមុន។



### 2. បំពេញការងារបន្ទាប់ពីធ្លាក់ព្រិលខ្លាំង (ព្រិលកម្រាស់ 25 ស.ម)

**បញ្ហាដែលត្រូវអនុវត្ត**

ចូរប្រយ័ត្នកុំឡើងលើដំបូលនៅពេលកំពុងធ្លាក់ព្រិល
និងនៅពេលអ្នកកាយព្រិលទម្លាក់។



## (8) បំពេញការងារនៅពេលមានរញ្ជួយដី (កម្រិតរំញ័រ 4 ឬលើសនេះ)




## បញ្ហាដែលត្រូវអនុវត្ត

1. កុំស្លន់ស្លោរ និងសូមគេចទៅទីមានសុវត្ថិភាព។
2. នៅពេលអ្នកបន្តការងារ ចូរពិនិត្យមើលសុវត្ថិភាពរន្ទា។
3. ចូរគិតអំពីដំណោះស្រាយក្នុងករណីមានរញ្ជួយដី។